# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

២៣-១១-២០១៦ -ព្រះរាជក្រម នស/រកម/១១១៦/០១៨ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពី ការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ ១០០១៩

### ២~ព្រះរាជក្រឹត្យ

១៧-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/១០៤៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម **ហោ ដារិទ្ធ** ១០០៦៥

១៧-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/១០៤៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចេង ស៊ូឆឹង** (CHENG SU CHEONG) ជនជាតិចិន សញ្ជាតិ ចិន ១០០៦៦

១៧-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/១០៥០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ឃុនចំក្រ ស៊ុដា** (KUNACHAK SUDA) ជនជាតិថៃ សញ្ជាតិថៃ ១០០៦៧

១៧-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/១០៥១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **រ៉េន គី** (REN KE) ជនជាតិចិន សញ្ជាតិចិន ១០០៦៨

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៧-១២-២០១៦ -អនុក្រឹត្យលេខ ២៤៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០០៦៩

០៩-១២-២០១៦ -អនុក្រឹត្យលេខ ២៥០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០០៧១

០៦-១២-២០១៦ -អនុក្រឹត្យលេខ ១១៨២ អនក្រ.តត ស្តីពី ការតែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការ ១០០៧៣

០៦-១២-២០១៦ -អនុក្រឹត្យលេខ ១១៨៣ អនក្រ.តត ស្ដីពី ការតែងតាំង ផ្ទេរ និងសម្រួលតួនាទីមន្ត្រីរាជការ ១០០៧៥
០៦-១២-២០១៦ -អនុក្រឹត្យលេខ ១១៨៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ១០០៧៨
០៦-១២-២០១៦ -អនុក្រឹត្យលេខ ១១៨៥ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០០៧៩

## III-ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-១០-២០១៦ -ប្រកាសលេខ ៨៧៥១ .សហវ.អគរ ស្ដីពី ការធ្វើបច្ចុប្បន្នភាពឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្ដីពី ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ តាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ានឆ្នាំ ២០០៧ (AHTN 2007) ឱ្យស៊ីចង្វាក់ជាមួយ AHTN 2017 វិញ

ត មកពីរាជកិច្ចលេខ ៨៧ ១០០៨០

# ព្រះរាជក្រម

នស/រកម/១១១៦/០១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គភាព
## ស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក ៣

មាត្រា ១.–

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន បូក ៣ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក នាថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តការលើនីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦

នស/រកម.១១១៦.០២៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខ: ១០៨៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# កិច្ចព្រមព្រៀងបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO)

## ភាគីនៃកិច្ចព្រមព្រៀង

**យោងតាម** ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (តទៅនេះហៅថា CMIM) ដើម្បីបង្កើតឱ្យមានយន្តការគាំទ្រសន្ទនីយភាពពហុភាគីនៅក្រោមក្របខ័ណ្ឌអាស៊ានបូក៣ ដើម្បីដោះស្រាយបញ្ហាលំបាកផ្នែកសន្ទនីយភាពរយៈពេលខ្លី និងជញ្ជឹងទូទាត់ក្នុងតំបន់

**ដោយហេតុថា** ភាគីទាំងអស់របស់ CMIM បានព្រមព្រៀងបង្កើតអង្គភាពតាមដានម៉ាក្រូសេដ្ឋកិច្ចក្រោមក្របខ័ណ្ឌ CMIM

**ដោយទទួលស្គាល់ថា** អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (តទៅនេះហៅថា AMRO Ltd) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ ផ្អែកតាមគំនិតផ្តួចផ្តើមនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានបូក៣

**ដោយមានបំណង** បង្កើត AMRO ជាអង្គការអន្តរជាតិដែលមានបុគ្គលភាពគតិយុត្តិពេញលេញដើម្បីបំពេញតួនាទីជា AMRO Ltd ដើម្បីឱ្យអង្គភាពនេះអាចដំណើរការប្រកបដោយប្រសិទ្ធភាពក្នុងនាមជាអង្គភាពតាមដានម៉ាក្រូសេដ្ឋកិច្ចឯករាជ្យក្នុងតំបន់ និង

**ដោយជឿជាក់ថា** ការបង្កើត AMRO គឺជាការបោះជំហានទៅមុខដ៏សំខាន់មួយក្នុងការជំរុញកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ តាមរយៈស្ថាប័នអចិន្ត្រៃយ៍មួយដែលគាំទ្រស្ថិរភាពហិរញ្ញវត្ថុក្នុងតំបន់ព្រមជាមួយនឹង CMIM ដ៏រឹងមាំមួយ

បានព្រមព្រៀងដូចខាងក្រោម ÷

## ជំពូក ១
## ការបង្កើត មុខងារ និងគោលបំណង
### មាត្រា ១ : ការបង្កើត និងសមាជិក

(១) តាមរយៈកិច្ចព្រមព្រៀងនេះ ភាគីនៃកិច្ចព្រមព្រៀងបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (តទៅនេះហៅថា AMRO) ជាស្ថាប័នអន្តរជាតិមួយដែលមានបុគ្គលភាពគតិយុត្តិពេញលេញ និងសមត្ថកិច្ចស្របច្បាប់ក្នុងការអនុវត្តមុខងារ និងគោលបំណងរបស់ខ្លួន ។

(២) ភាគីនៃកិច្ចព្រមព្រៀងដែលបានផ្តល់សច្ចាប័ន ឯកភាព ឬអនុម័តលើកិច្ចព្រមព្រៀងនេះ នឹងក្លាយជាសមាជិកនៃ AMRO ស្របតាមមាត្រា ២៥ និង ២៦ ។

### មាត្រា ២ : គោលបំណង

គោលបំណងរបស់ AMRO គឺរួមចំណែកធានាស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ តាមរយៈការតាមដានម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ និងគាំទ្រការអនុវត្តយន្តការហិរញ្ញវត្ថុក្នុងតំបន់ ។ វាក្យសព្ទ "យន្តការហិរញ្ញវត្ថុក្នុងតំបន់" មានន័យថាយន្តការគាំទ្រសន្ទនីយភាពពហុភាគីនៅក្រោមក្របខ័ណ្ឌអាស៊ានបូក ៣ ដើម្បីដោះស្រាយបញ្ហាលំបាកបច្ចុប្បន្ន និងអនាគតនៃសន្ទនីយភាពរយៈពេលខ្លី និងនៃជញ្ជីងទូទាត់ក្នុងតំបន់។

### មាត្រា ៣ : មុខងារ

ដើម្បីបំពេញគោលបំណងរបស់ខ្លួន AMRO ត្រូវមានមុខងារដូចខាងក្រោម ÷

ក. ពិនិត្យ វាយតម្លៃ និងរាយការណ៍ជូនសមាជិកពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងភាពរឹងមាំហិរញ្ញវត្ថុ

ខ. កំណត់ហានិភ័យម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាពងាយរងគ្រោះក្នុងតំបន់ ហើយជួយសមាជិកតាមការស្នើសុំក្នុងការបង្កើតនូវអនុសាសន៍គោលនយោបាយ ដើម្បីកាត់បន្ថយហានិភ័យទាំងនោះឱ្យទាន់ពេលវេលា

គ. គាំទ្រសមាជិកក្នុងការអនុវត្តយន្តការហិរញ្ញវត្ថុក្នុងតំបន់ និង

ឃ. ដឹកនាំសកម្មភាពចាំបាច់នានាដើម្បីសម្រេចគោលបំណងរបស់ AMRO ដូចបានកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

## ជំពូក ២
## ប្រតិបត្តិការ

### មាត្រា ៤ : កិច្ចសហប្រតិបត្តិការនៃសមាជិក

(១) សមាជិកនីមួយៗត្រូវផ្តល់ជូន AMRO នូវព័ត៌មានពាក់ព័ន្ធនិងកិច្ចសហការចាំបាច់សម្រាប់តាមដានម៉ាក្រូសេដ្ឋកិច្ច និងសកម្មភាពនានាដូចមានចែងក្នុងមាត្រា ៣ ក្នុងដែនកំណត់ដែលអនុញ្ញាត

ដោយច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសសមាជិក ។ សមាជិកទាំងអស់មិនមានកាតព្វកិច្ចផ្តល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងកិច្ចការបុគ្គល ឬក្រុមហ៊ុនឡើយ។

(២) សមាជិកនីមួយៗត្រូវសហការដោយស្មោះត្រង់ជាមួយ AMRO ក្នុងការតាមដានរបស់ AMRO និងសកម្មភាពផ្សេងៗដូចមានចែងក្នុងមាត្រា ៣។

### មាត្រា ៥ : ប្រតិបត្តិការ

ដើម្បីបំពេញមុខងារ និងគោលបំណងក្នុងមាត្រា ២ និង ៣÷

ក. AMRO ត្រូវប្រើប្រាស់ព័ត៌មានដែលសមាជិកទាំងអស់ផ្តល់ឱ្យក្នុងមាត្រា ៤ ឱ្យបានសមស្រប

ខ. AMRO អាចរៀបចំពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយសមាជិកនីមួយៗ (បេសកកម្មពិគ្រោះយោបល់ប្រចាំឆ្នាំ) អំពីបញ្ហាពាក់ព័ន្ធនឹងមុខងារ និងគោលបំណងរបស់ AMRO ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

គ. AMRO ត្រូវមានឯករាជ្យភាព និងមិនស្ថិតនៅក្រោមឥទ្ធិពលនៃសមាជិកណាមួយ ក្នុងការរៀបចំរបាយការណ៍ចាំបាច់នានា ក្នុងការអនុវត្តមុខងារ និងគោលបំណងរបស់ខ្លួន ហើយធ្វើការទំនាក់ទំនងជាសម្ងាត់ និងក្រៅផ្លូវការជាមួយសមាជិកណាមួយអំពីបញ្ហាកើតមានឡើងនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលអាចប៉ះពាល់ដល់សមាជិកនោះ

ឃ. AMRO ត្រូវបោះផ្សាយជាសាធារណៈនូវរបាយការណ៍ចាំបាច់នានា ក្នុងការអនុវត្តមុខងារ និងគោលបំណងរបស់ខ្លួន ស្របតាមអនុកថាខណ្ឌទី២ ចំណុច (ច) នៃមាត្រា ៨ និង

ង. AMRO អាចសហការជាមួយសមាជិក អង្គភាព ឬស្ថាប័នអន្តរជាតិក្នុងវិស័យពាក់ព័ន្ធស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ និងអាចចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នទាំងនោះ។ គ្មានសមាជិកណាមួយត្រូវទទួលខុសត្រូវចំពោះទង្វើ កំហុសឆ្គង ឬកាតព្វកិច្ចរបស់ AMRO ដែលកើតចេញពីកិច្ចព្រមព្រៀងនេះ ដោយហេតុផលតួនាទី ឬការចូលរួមរបស់ខ្លួននៅក្នុង AMRO។

## ជំពូក ៣

## អភិបាលកិច្ច

### មាត្រា ៦ : រចនាសម្ព័ន្ធ

AMRO ត្រូវមានគណៈកម្មាធិការប្រតិបត្តិ ក្រុមពិគ្រោះយោបល់ ប្រធាន និងបុគ្គលិក ។

## មាត្រា ៧ : សមាសភាពគណៈកម្មាធិការប្រតិបត្តិ

(១) សមាជិកនីមួយៗ ត្រូវមានតំណាងចំនួន ២ រូប នៅក្នុងគណៈកម្មាធិការប្រតិបត្តិ ÷ អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ ១ រូប មកពីរដ្ឋាភិបាលដែលទទួលខុសត្រូវខាងផ្នែកហិរញ្ញវត្ថុ និងទេសាភិបាលរង ១ រូបមកពីធនាគារកណ្តាល ឬស្ថាប័នមានឋានៈប្រហាក់ប្រហែល។ រាល់ការតែងតាំងអាចត្រូវបានលុបចោលគ្រប់ពេលដោយសមាជិកដែលធ្វើការតែងតាំង ។

(២) អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ ឬទេសាភិបាលរងធនាគារកណ្តាលនីមួយៗ អាចតែងតាំងអ្នកជំនួសដែលមានសិទ្ធិពេញលេញក្នុងការបំពេញការងារជំនួសនៅពេលដែលខ្លួនអវត្តមាន ។

(៣) ទោះបីជាមានកថាខណ្ឌ ១ និងកថាខណ្ឌ ២ ខាងលើក៏ដោយ តំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន (តទៅនេះហៅថា ហុងកុង ប្រទេសចិន) អាចតែងតាំងអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ ឬទេសាភិបាលរងធនាគារកណ្តាល ១ រូប ប៉ុណ្ណោះ ។

## មាត្រា ៨ : អំណាច និងនីតិវិធីរបស់គណៈកម្មាធិការប្រតិបត្តិ

(១) រាល់អំណាចរបស់ AMRO ក្រោមកិច្ចព្រមព្រៀងនេះ ដែលមិនត្រូវបានលើកមកពិភាក្សាជាមួយក្រុមពិគ្រោះយោបល់ ឬប្រធានទេ ត្រូវផ្ទេរជូនគណៈកម្មាធិការប្រតិបត្តិដើម្បីពិភាក្សា ។

(២) គណៈកម្មាធិការប្រតិបត្តិត្រូវរក្សាការត្រួតពិនិត្យជាយុទ្ធសាស្ត្រនិងកំណត់ទិសដៅគោល-នយោបាយសម្រាប់ AMRO និងជាពិសេស ÷

- ក. ពិនិត្យឡើងវិញនូវរបាយការណ៍ដែលត្រូវបានរៀបចំឡើងក្រោមមាត្រា ៣ និងមាត្រា ៥ និងរបាយការណ៍ផ្សេងទៀត ព្រមទាំងការវាយតម្លៃដែលរៀបចំដោយប្រធាន រួមទាំងធាតុចូលផ្តល់ដោយក្រុមពិគ្រោះយោបល់ផងដែរ
- ខ. ពិនិត្យឡើងវិញ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដែលបង្ហាញអំពីការអនុវត្តមុខងារ និងភារកិច្ចរបស់ AMRO រួមមានរបាយការណ៍សវនកម្មលើគណនីហិរញ្ញវត្ថុ និងក្របខ័ណ្ឌបុគ្គលិករបស់ AMRO
- គ. ពិនិត្យឡើងវិញ និងអនុម័តលើសមត្ថភាពបុគ្គលិក ថវិកាប្រចាំឆ្នាំ និងកម្មវិធីការងាររបស់ AMRO
- ឃ. ត្រួតពិនិត្យដំណើរការតែងតាំង ព្យួរ ឬបញ្ឈប់ការងាររបស់ប្រធាន ដោយអនុលោមតាមមាត្រា ១១ តាមការចាំបាច់ និងពិនិត្យឡើងវិញការអនុវត្តការងាររបស់ប្រធាន

ង. តែងតាំងសមាជិកក្រុមពិគ្រោះយោបល់ និងព្យួរ ឬបញ្ឈប់ការតែងតាំងណាមួយ និង

ច. កំណត់គោលនយោបាយបោះពុម្ពផ្សាយរបស់ AMRO ។

(៣) គណៈកម្មាធិការប្រតិបត្តិអាចប្រកាសឱ្យប្រើនូវវិធាន បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធី តាមការចាំបាច់ ឬសមស្រប ដើម្បីអនុវត្តការងាររបស់ AMRO ។

(៤) គណៈកម្មាធិការប្រតិបត្តិអាចបង្កើតគណៈកម្មាធិការផ្សេងទៀតតាមការចាំបាច់និងសមស្រប ដើម្បីសម្រួលប្រតិបត្តិការទូទៅរបស់ AMRO ។

(៥) គណៈកម្មាធិការប្រតិបត្តិត្រូវជួបប្រជុំជាប្រចាំតាមពេលវេលា និងទីកន្លែងដែលបានកំណត់ និងត្រូវមានអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាលចំនួន ២ រូបមកពីប្រទេសសម្រប សម្រួលទាំងពីរ ធ្វើជាសហប្រធានអង្គប្រជុំរួមគ្នា ដែលក្នុងនោះ ១ រូបមកពីប្រទេសសមាជិកអាស៊ាន និង ១ រូបទៀតមកពីប្រទេសក្នុងចំណោមសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ។

## មាត្រា ៩ : ការបោះឆ្នោត

(១) កូរ៉ុមសម្រាប់កិច្ចប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវមានចំនួនភាគច្រើននៃអនុរដ្ឋមន្ត្រី ហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាល ដែលត្រូវមានសម្លេងបោះឆ្នោតមិនតិចជាង២ភាគ៣នៃ សម្លេងបោះឆ្នោតសរុប ដូចមានចែងក្នុងតារាងនៃកិច្ចព្រមព្រៀងនេះ ។

(២) ការសម្រេចចិត្តរបស់គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើឡើងដោយមតិឯកច្ឆ័ន្ទ ។ បើគ្មានមតិ ឯកច្ឆ័ន្ទទេ ការសម្រេចចិត្តរបស់គណៈកម្មាធិការប្រតិបត្តិមានប្រសិទ្ធភាពលុះត្រាតែត្រូវបានអនុម័តតាម សម្លេងបោះឆ្នោតមិនតិចជាង២ភាគ៣ នៃសម្លេងបោះឆ្នោតសរុប ដូចមានចែងក្នុងតារាងនៃកិច្ចព្រមព្រៀងនេះ។

(៣) នៅពេលអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាលតំណាងឱ្យសមាជិកមួយ តំណាងទាំងពីរនេះ ត្រូវបោះឆ្នោតតែមួយសម្លេងប៉ុណ្ណោះ ។ ដើម្បីជៀសវាងការភាន់ច្រឡំ ការបោះឆ្នោត របស់សាធារណរដ្ឋប្រជាមានិតចិន និងហុងកុង ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា ។

## មាត្រា ១០ : ក្រុមពិគ្រោះយោបល់

(១) ក្រុមពិគ្រោះយោបល់ត្រូវផ្តល់ធាតុចូលដែលមានលក្ខណៈយុទ្ធសាស្ត្រ បច្ចេកទេស និងវិជ្ជាជីវៈ ឱ្យទាន់ពេលវេលា លើការវាយតម្លៃម៉ាក្រូសេដ្ឋកិច្ចរបស់ AMRO និងផ្តល់អនុសាសន៍ដល់ប្រធាន ។

(២) ក្រុមពិគ្រោះយោបល់ត្រូវមានឯករាជ្យភាពពីប្រធាន និងបុគ្គលិករបស់ AMRO និងត្រូវទទួលខុសត្រូវចំពោះគណៈកម្មាធិការប្រតិបត្តិ ។

(៣) ក្រុមពិគ្រោះយោបល់ត្រូវមានសមាជិកមិនលើសពី ៦ រូប ដែលជាសេដ្ឋវិទូជំនាញ និងមានការទទួលស្គាល់ ស្របតាមលក្ខខណ្ឌដែលគណៈកម្មាធិការប្រតិបត្តិកំណត់។ សមាជិកនៃក្រុមពិគ្រោះយោបល់ត្រូវតែងតាំងដោយគណៈកម្មាធិការប្រតិបត្តិ ។

## មាត្រា ១១ : ប្រធាន និងបុគ្គលិក

(១) គណៈកម្មាធិការប្រតិបត្តិត្រូវតែងតាំងប្រធាន ១ រូប ។ ប្រធានត្រូវបំពេញការងារដូចមានចែងក្នុងលក្ខន្តិកដែលកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

(២) ការតែងតាំងប្រធានត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍គុណូបធិបតេយ្យ តម្លាភាព និងបើកចំហ។

(៣) ប្រធានត្រូវចូលរួមក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការប្រតិបត្តិ លើកលែងតែមានការណែនាំផ្សេងពីនេះដោយគណៈកម្មាធិការប្រតិបត្តិ ។

(៤) ប្រធានត្រូវ ÷

ក. ផ្តល់ជូនគណៈកម្មាធិការប្រតិបត្តិនូវការវាយតម្លៃប្រចាំគ្រាអំពីម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងស្ថានភាពនិងគោលនយោបាយហិរញ្ញវត្ថុក្នុងតំបន់

ខ. ទទួលខុសត្រូវចំពោះគណៈកម្មាធិការប្រតិបត្តិ និងស្ថិតនៅក្រោមការគ្រប់គ្រងទូទៅរបស់គណៈកម្មាធិការនេះ

គ. ជាប្រធាននៃបុគ្គលិករបស់ AMRO ហើយទទួលខុសត្រូវលើការចាត់ចែង តែងតាំង និងបញ្ឈប់បុគ្គលិក និងដំណើរការទូទៅរបស់ AMRO លើកលែងតែគណៈកម្មាធិការប្រតិបត្តិសម្រេចផ្សេងពីនេះ

ឃ. តំណាងឱ្យ AMRO និងដឹកនាំការងារបច្ចុប្បន្នរបស់ AMRO

ង. ដាក់ជូនគណៈកម្មាធិការប្រតិបត្តិនូវរបាយការណ៍ប្រចាំឆ្នាំ និង

ច. ដាក់ជូនគណៈកម្មាធិការប្រតិបត្តិនូវផែនការជ្រើសរើសបុគ្គលិក គម្រោងថវិកាប្រចាំឆ្នាំ និងកម្មវិធីការងារប្រចាំឆ្នាំរបស់ AMRO ដើម្បីពិនិត្យ និងអនុម័ត ។

(៥) ប្រធាន និងបុគ្គលិកត្រូវបំពេញភារកិច្ចទៅតាមមុខងាររបស់ខ្លួនទាំងស្រុងជូន AMRO និងមិនអាចមានមុខងារក្នុងអង្គភាពផ្សេងទៀតឡើយ ។ សមាជិកទាំងអស់ត្រូវគោរពតាមចរិតលក្ខណៈជាអន្តរជាតិនៃកាតព្វកិច្ចនេះ និងមិនត្រូវប៉ុនប៉ងប្រើឥទ្ធិពលដល់បុគ្គលិកដទៃក្នុងការបំពេញមុខងារទាំងនេះឡើយ។

(៦) ក្នុងការតែងតាំងបុគ្គលិក ប្រធានត្រូវផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់ក្នុងការជ្រើសរើសបុគ្គលិកពីតំបន់ភូមិសាស្ត្រឱ្យបានទូលំទូលាយតាមលទ្ធភាពធ្វើទៅបាន ដោយធានានូវស្តង់ដារខ្ពស់បំផុតនៃប្រសិទ្ធភាព និងសមត្ថភាពបច្ចេកទេស ។

## មាត្រា ១២ : ការសម្ងាត់វិជ្ជាជីវៈ

អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាល និងតំណាងជំនួសរបស់ខ្លួន សមាជិកនៃក្រុមពិគ្រោះយោបល់ ប្រធាន និងបុគ្គលិក ជំនាញការដែលបំពេញបេសកកម្មជូន AMRO និងភាគីផ្សេងទៀតដែលបម្រើការ ឬបានបម្រើការជូន ឬមានទំនាក់ទំនងជាមួយ AMRO មិនត្រូវបញ្ចេញព័ត៌មានដែលទទួលបានក្នុងពេលបំពេញភារកិច្ច ឬមុនពេលបំពេញភារកិច្ចរបស់ខ្លួន លើកលែងមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ។ កាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់នៃព័ត៌មានត្រូវបន្តអនុវត្តបន្ទាប់ពីភារកិច្ចរបស់ខ្លួនជាមួយ AMRO ត្រូវបានបញ្ចប់។ នៅក្នុងកិច្ចព្រមព្រៀងនេះ វាក្យសព្ទ "ជំនាញការដែលបំពេញបេសកកម្មជូន AMRO" សំដៅលើអ្នកមានវិជ្ជាជីវៈដែលអនុវត្តតាមគោលបំណង និងមុខងាររបស់ AMRO ក្រោមកិច្ចសន្យាជាមួយ AMRO។

## មាត្រា ១៣ : ថវិកា និងហិរញ្ញវត្ថុ

(១) AMRO ត្រូវបានផ្តល់ជូននូវធនធានហិរញ្ញវត្ថុចាំបាច់ដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

(២) AMRO ត្រូវបង្កើតវិធាន និងនីតិវិធីហិរញ្ញវត្ថុ ស្របតាមស្តង់ដារអន្តរជាតិ ។ AMRO ត្រូវគោរពគោលការណ៍ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្ន និងការគ្រប់គ្រងថវិកាស្របតាមឧត្តមានុភាពអន្តរជាតិ ។

(៣) ការចំណាយទាក់ទងនឹងការិយាល័យ គឺជាបន្ទុករបស់សាធារណរដ្ឋសិង្ហបុរីដែលជាប្រទេសម្ចាស់ផ្ទះ និងត្រូវធ្វើការផ្ទេរថវិកាឱ្យទាន់ពេលវេលា ដោយឈរលើមូលដ្ឋានសមស្រប ។

(៤) រាល់ការចំណាយផ្សេងទៀត (រួមមាន តែមិនកម្រិតចំពោះតែការចំណាយពាក់ព័ន្ធនឹងធនធានមនុស្ស) គឺជាបន្ទុករបស់ប្រទេសសមាជិក ដោយអនុលោមតាមការបង់ភាគទាន តាមចំណែករបស់ប្រទេសសមាជិកនីមួយៗ ដូចបានកំណត់នៅក្នុងកម្មវិធីនៃកិច្ចព្រមព្រៀងនេះ។ ប្រទេសសមាជិកត្រូវបង់ភាគទានរបស់ខ្លួនឱ្យបានទាន់ពេលវេលានៅពេលទទួលបានការអនុម័តលើគម្រោងថវិកាប្រចាំឆ្នាំដែលបានបម្រុងទុក។

(៥) AMRO មិនអាចខ្ចីប្រាក់បានឡើយ លើកលែងតែមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិជាមុនសិន ។

## មាត្រា ១៤ : ការប្រាស្រ័យទាក់ទង

(១) ប្រទេសសមាជិកនីមួយៗអាចជ្រើសរើសអង្គភាពផ្លូវការចំនួនពីរ ដែលអាចឱ្យ AMRO ធ្វើការប្រាស្រ័យទាក់ទងជាមួយបាន ក្នុងករណីមានបញ្ហាណាមួយកើតមានឡើងក្រោមកិច្ចព្រមព្រៀងនេះ។ AMRO ត្រូវដោះស្រាយបញ្ហាទាំងនោះ តាមរយៈការទាក់ទងជាមួយអង្គភាពផ្លូវការដែលបានកំណត់ខាងលើ។

(២) ក្នុងករណីតម្រូវឱ្យមានការអនុម័តដោយសមាជិកណាមួយក្រោមកិច្ចព្រមព្រៀងនេះ មុនពេល AMRO អាចធ្វើសកម្មភាពណាមួយ ការអនុម័តត្រូវបានចាត់ទុកថាបានផ្តល់ជូន លើកលែងសមាជិកនោះធ្វើការជំទាស់ជាលាយលក្ខណ៍អក្សរតាមពេលវេលាសមរម្យ ដែលអាចត្រូវបានកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ នៅពេល AMRO ជូនដំណឹងទៅកាន់សមាជិកនោះពីសកម្មភាពដែលខ្លួនចង់ធ្វើ ។

(៣) ភាសាផ្លូវការរបស់ AMRO គឺភាសាអង់គ្លេស ។

## មាត្រា ១៥ : ទីតាំង

ទីស្នាក់ការកណ្តាលរបស់ AMRO ត្រូវស្ថិតនៅក្នុងសាធារណរដ្ឋសឹង្ហបុរី ។

# ជំពូក ៤

# លក្ខខណ្ឌគតិយុត្តិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

## មាត្រា ១៦ : គោលបំណងនៃលក្ខខណ្ឌគតិយុត្តិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

លក្ខខណ្ឌគតិយុត្តិ បុព្វសិទ្ធិ អភ័យឯកសិទ្ធិ និងការលើកលែងដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវផ្តល់ឱ្យ AMRO នៅក្នុងដែនដីនៃប្រទេសសមាជិកនីមួយៗ ដើម្បីអនុញ្ញាតឱ្យ AMRO បំពេញគោលបំណង និងមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

## មាត្រា ១៧ : លក្ខខណ្ឌគតិយុត្តិរបស់ AMRO

AMRO ត្រូវមានបុគ្គលភាពគតិយុត្តិពេញលេញ ជាពិសេសមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការ÷

(ក) ចុះកិច្ចសន្យា

(ខ) ទិញ និងលក់ចលនទ្រព្យ និងអចលនទ្រព្យ និង

(គ) រៀបចំពាក្យបណ្តឹង

## មាត្រា ១៨ : បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ AMRO

(១) AMRO ត្រូវទទួលបានអភ័យឯកសិទ្ធិពីគ្រប់ទម្រង់នៃដំណើរការច្បាប់ លើកលែងតែខ្លួនបោះបង់ចោលអភ័យឯកសិទ្ធិក្នុងគោលបំណងនៃការប្តឹងតវ៉ា ឬក្រោមលក្ខខណ្ឌនៃកិច្ចសន្យាណាមួយ ។

(២) ទ្រព្យសម្បត្តិ និងទ្រព្យសកម្មរបស់ AMRO ទោះបីជានៅទីកន្លែងណា ឬកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យឯកសិទ្ធិរួចផុតពីការឆែកឆេរ ការដកហូតបណ្តោះអាសន្ន ការរឹបអូសអស្សាមីករណ៍ ឬការរឹបអូសក្រោមទម្រង់ផ្សេងៗទៀត ដោយវិធានការនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ។

(៣) ប័ណ្ណសាររបស់ AMRO និងឯកសារទាំងអស់ដែលជាកម្មសិទ្ធិរបស់ ឬកាន់កាប់ដោយ AMRO មិនអាចរំលោភបំពានបានឡើយ ។

(៤) ក្នុងករណីចាំបាច់ក្នុងការអនុវត្តមុខងាររបស់ខ្លួនរាល់ទ្រព្យសម្បត្តិ និងទ្រព្យសកម្មរបស់ AMRO ត្រូវរួចផុតពីការដាក់កំហិត ការដាក់បទប្បញ្ញត្តិ ការត្រួតពិនិត្យ និងការបង្អាក់ទុកក្រោមរូបភាពណាក៏ដោយ ។

(៥) ប្រទេសសមាជិកនីមួយៗត្រូវធ្វើការប្រាស្រ័យទាក់ទងផ្លូវការជាមួយ AMRO ឱ្យស្មើភាពគ្នាដូចធ្វើការប្រាស្រ័យទាក់ទងជាផ្លូវការរបស់ខ្លួនចំពោះសមាជិកដទៃៗទៀត។

(៦) គ្មានការដាក់ទោសទណ្ឌណាមួយចំពោះការឆ្លើយឆ្លងព័ត៌មានផ្លូវការ និងការប្រាស្រ័យទាក់ទងគ្នាជាផ្លូវការផ្សេងទៀតរបស់ AMRO នោះទេ។ គ្មានចំណុចណាមួយក្នុងមាត្រានេះត្រូវបានបកស្រាយដើម្បីច្រានចោលការអនុម័តការការពារសុវត្ថិភាពជាមុនដែលកំណត់ដោយការព្រមព្រៀងរវាងសមាជិកនិង AMRO នោះទេ ។

(៧) ទ្រព្យសកម្ម ទ្រព្យសម្បត្តិ ប្រាក់ចំណូល និងរាល់ប្រតិបត្តិការរបស់ AMRO ត្រូវបានលើកលែងពីការបង់ពន្ធដារ និងពន្ធគយទាំងអស់ ។ AMRO ក៏ត្រូវបានលើកលែងផងដែរពីកាតព្វកិច្ចបង់ពន្ធកាត់ទុក

ឬការប្រមូលពន្ធអាករនានា ។ ទោះបីយ៉ាងណាក៏ដោយ AMRO មិនអាចទាមទារការលើកលែងពន្ធលើចំណាយទឹក ភ្លើង និងសេវាទូរស័ព្ទជាដើមបានទេ ។

## មាត្រា ១៩ : បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បុគ្គលិក AMRO

អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាល និងតំណាងជំនួសរបស់ខ្លួន សមាជិកនៃក្រុមពិគ្រោះយោបល់ ប្រធាន និងបុគ្គលិក ជំនាញការដែលបំពេញបេសកកម្មជូន AMRO (តទៅនេះហៅថាបុគ្គលិក AMRO) ÷

ក. ត្រូវទទួលបានអភ័យឯកសិទ្ធិពីវិវាទតាមផ្លូវច្បាប់ដែលទាក់ទងនឹងពាក្យសម្តី ឬពាក្យពេជន៍ជាលាយលក្ខណ៍អក្សរ និងទង្វើដែលពួកគេបានប្រព្រឹត្តក្នុងដែនសមត្ថកិច្ចផ្លូវការរបស់ពួកគេ ព្រមទាំងទទួលបានសិទ្ធិការពារពីការរំលោភបំពានលើឯកសារផ្លូវការរបស់ខ្លួន លើកលែងតែ AMRO ដកហូតអភ័យឯកសិទ្ធិនេះវិញ ។

ខ. ក្នុងករណីមិនមែនជាប្រជាពលរដ្ឋ ឬជាតិសាសន៍ក្នុងស្រុក ត្រូវទទួលបានអភ័យឯកសិទ្ធិដូចគ្នាពីការដាក់កំហិតអន្តោប្រវេសន៍ ការតម្រូវឱ្យចុះឈ្មោះជាជនបរទេស និងកាតព្វកិច្ចជាតិ និងមធ្យោបាយដូចគ្នាចំពោះលក្ខខណ្ឌដោះដូររវាងសមាជិកនីមួយៗ ដែលត្រូវបានផ្តល់ជូនដល់អ្នកតំណាង និងបុគ្គលិកដែលមានឋានៈប្រហាក់ប្រហែលរបស់សមាជិកដទៃទៀត

គ. ត្រូវទទួលបាននូវប្រព្រឹត្តិកម្មដូចគ្នាចំពោះមធ្យោបាយធ្វើដំណើរដូចដែលប្រទេសសមាជិកនីមួយៗ យល់ព្រមផ្តល់ជូនអ្នកតំណាងនិងបុគ្គលិកដែលមានឋានៈប្រហាក់ប្រហែលរបស់សមាជិកដទៃទៀត និង

ឃ. ក្នុងករណីមិនមែនជាប្រជាពលរដ្ឋ ឬជាតិសាសន៍ក្នុងស្រុក ត្រូវបានលើកលែងពីការយកពន្ធលើប្រាក់បៀវត្ស និងបរិលាភដែលទទួលបានពី AMRO ។

## មាត្រា ២០ : ការអនុវត្ត

(១) សមាជិកនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីផ្តល់ប្រសិទ្ធភាពដល់លក្ខខណ្ឌគតិយុត្តិ បុព្វសិទ្ធិ អភ័យឯកសិទ្ធិ ការលើកលែង និងមធ្យោបាយនានារបស់ AMRO និងបុគ្គលិក AMRO នៅក្នុងប្រទេសរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១៧, ១៨, និង ១៩ និងត្រូវជូនដំណឹងមក AMRO ពីវិធានការដែលបានអនុវត្តចំពោះកិច្ចការនេះ ។

(២) ថ្វីបើមានបញ្ញត្តិផ្សេងទៀតក្នុងកិច្ចព្រមព្រៀងនេះក៏ដោយ ក្នុងដែនដីដែល AMRO មិនស្ថិតនៅ លក្ខខណ្ឌគតិយុត្តិ បុព្វសិទ្ធិ អភ័យឯកសិទ្ធិ ការលើកលែង និងមធ្យោបាយនានាដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ អាចត្រូវបានផ្តល់ជូន AMRO និងបុគ្គលិក AMRO តាមកម្រិតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិនៃសមាជិកនីមួយៗ ។ ទោះជាយ៉ាងណាក៏ដោយ បុព្វសិទ្ធិ អភ័យឯកសិទ្ធិ ការលើកលែង និងមធ្យោបាយនានា ដូចមានចែងក្នុងមាត្រា ១៨ និង ១៩ ត្រូវគោរពដោយសមាជិកទាំងអស់ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ AMRO ដូចបានកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

(៣) បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះមិនអាចដាក់កំហិត ឬរើសអើងចំពោះបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលអាចត្រូវបានផ្តល់ជូនដោយសមាជិកណាមួយដល់ AMRO និងបុគ្គលិក AMRO ដោយហេតុផលនៃទីតាំង AMRO ក្នុងដែនដីរបស់សមាជិកនោះឡើយ ។ កិច្ចព្រមព្រៀងនេះមិនត្រូវប្រើប្រាស់ដើម្បីរារាំងដល់សមាជិកណាមួយ និង AMRO ក្នុងការចុះកិច្ចព្រមព្រៀងបន្ថែមនានា រួមមានកិច្ចព្រមព្រៀងស្តីពីការកែសម្រួលបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងស្តីពីការពង្រីក ឬការបង្រួមនូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលបានផ្តល់ជូន ។

## មាត្រា ២១ : ការដកអភ័យឯកសិទ្ធិ

(១) បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិត្រូវបានផ្តល់ជូនបុគ្គលិក AMRO ដើម្បីជាប្រយោជន៍របស់ AMRO តែប៉ុណ្ណោះ និងមិនមែនសម្រាប់ផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួននោះទេ ។

(២) គណៈកម្មាធិការប្រតិបត្តិ អាចដកអភ័យឯកសិទ្ធិពីអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាល និងតំណាងជំនួសរបស់ខ្លួន សមាជិកនៃក្រុមពិគ្រោះយោបល់ និងប្រធានតាមទំហំ និងលក្ខខណ្ឌ ដូចបានកំណត់ក្នុងជំពូកនេះ ។

(៣) ប្រធានអាចដកអភ័យឯកសិទ្ធិពីបុគ្គលិក និងអ្នកជំនាញការដែលបំពេញបេសកកម្មជូន AMRO ក្រៅពីខ្លួនឯង ។

(៤) AMRO ត្រូវសហការគ្រប់ពេលជាមួយអាជ្ញាធររបស់ប្រទេសសមាជិក ដើម្បីសម្រួលរដ្ឋបាលយុត្តិធម៌សមស្រប ធានាការគោរពតាមបទប្បញ្ញត្តិនគរបាល គោរព និងអនុវត្តតាមច្បាប់ក្នុងស្រុក និងរារាំងករណីរំលោភបំពានណាមួយដែលពាក់ព័ន្ធនឹងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

## ជំពូក ៥

## អវសានប្បញ្ញត្តិ

### មាត្រា ២២ : វិសោធនកម្ម

(១) សមាជិកអាចស្នើសុំគណៈកម្មាធិការប្រតិបត្តិដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ។

(២) គណៈកម្មាធិការប្រតិបត្តិអាចអនុម័តសំណើវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះក្នុងករណីដែលមានមតិឯកច្ឆ័ន្ទពីអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលរងធនាគារកណ្តាល ។ ដើម្បីជៀសវាងភាពមន្ទិលសង្ស័យ កថាខណ្ឌ (២) នៃមាត្រា ៩ ទាក់ទងនឹងការបោះឆ្នោតដោយគណៈកម្មាធិការប្រតិបត្តិ នឹងមិនត្រូវអនុវត្តចំពោះមាត្រានេះទេ ។

(៣) វិសោធនកម្មនៃកិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមាន ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលសមាជិកទាំងអស់បានផ្តល់សច្ចាប័ន ឯកភាព ឬអនុម័តលើវិសោធនកម្ម ។ លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័តលើវិសោធនកម្ម ត្រូវបានអនុវត្តតាមនីតិវិធីដែលមានចែងក្នុងមាត្រា ២៥ ។

### មាត្រា ២៣ : ការបកស្រាយ និងការដោះស្រាយវិវាទ

**(១)** សមាជិកត្រូវព្យាយាមដោះស្រាយវិវាទពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងនេះតាមរយៈការចរចាក្នុងរយៈពេល ៦ ខែ បន្ទាប់ពីពេលកើតមានវិវាទ ។

**(២)** រាល់វិវាទទាំងឡាយណាដែលមិនអាចដោះស្រាយបានតាមកថាខណ្ឌ (១) ខាងលើត្រូវដាក់ជូនគណៈកម្មាធិការប្រតិបត្តិ ដែលជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ ។

**(៣)** ប្រសិនបើវិវាទកើតឡើងរវាង AMRO និងរដ្ឋាភិបាលមួយដែលបានបញ្ចប់សមាជិកភាព ឬរវាង AMRO និងសមាជិកណាមួយបន្ទាប់ពីបានបញ្ចប់ប្រតិបត្តិការរបស់ AMRO វិវាទនេះត្រូវដាក់ជូនមជ្ឈត្តកម្មដែលជាសាលាក្តីមានមជ្ឈត្តករចំនួន ៣ រូប ដែល ១ រូប តែងតាំងដោយ AMRO ១ រូបទៀតតែងតាំងដោយអតីតសមាជិក ឬរដ្ឋាភិបាលពាក់ព័ន្ធ និងអ្នកទី៣ត្រូវតែងតាំងដោយប្រធានតុលាការយុត្តិធម៌អន្តរជាតិ ឬអាជ្ញាធរផ្សេងទៀត ដូចបានកំណត់នៅក្នុងបទប្បញ្ញត្តិដែលអនុម័តដោយគណៈកម្មាធិការប្រតិបត្តិ លើកលែងមានការជំទាស់ពីភាគីណាមួយ ។ សម្លេងបោះឆ្នោតភាគច្រើននៃមជ្ឈត្តករត្រូវមានគ្រប់គ្រាន់ ដើម្បីឈានដល់សេចក្តីសម្រេចចុងក្រោយ និងត្រូវអនុវត្តដោយភាគីទាំងអស់ ។ មជ្ឈត្តករទី៣ ត្រូវ

ទទួលបានសិទ្ធិអំណាចក្នុងការដោះស្រាយរាល់បញ្ហាទាំងអស់ទាក់ទងនឹងនីតិវិធីនៃរឿងក្តី នៅពេលដែលភាគីណាមួយមិនយល់ស្របតាមសេចក្តីសម្រេចខាងលើ ។

### មាត្រា ២៤ : ហត្ថលេខានិងការតម្កល់កិច្ចព្រមព្រៀង

(១) ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះដែលធ្វើមួយច្បាប់ជាភាសាអង់គ្លេស ត្រូវចុះហត្ថលេខាដោយភាគីនៃកិច្ចព្រមព្រៀង (តទៅនេះហៅថា "ហត្ថលេខី") ដែលនឹងត្រូវតម្កល់កិច្ចព្រមព្រៀងនេះជាមួយអគ្គលេខាធិការនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (តទៅនេះហៅថា "កន្លែងតម្កល់កិច្ចព្រមព្រៀង") ។

(២) កន្លែងតម្កល់កិច្ចព្រមព្រៀងត្រូវផ្ញើជូនច្បាប់ចម្លងនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារួចហើយ និងបានបញ្ជាក់ត្រឹមត្រូវដល់ហត្ថលេខីទាំងអស់ ។

### មាត្រា ២៥ : ការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័ត

(១) កិច្ចព្រមព្រៀងនេះត្រូវជាកម្មវត្ថុចំពោះការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័ត ដោយហត្ថលេខីទាំងអស់ ។ លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័ត ត្រូវតម្កល់នៅកន្លែងតម្កល់កិច្ចព្រមព្រៀងដែលត្រូវជូនដំណឹងដល់ហត្ថលេខីទាំងអស់អំពីកាលបរិច្ឆេទនៃការតម្កល់ឧបករណ៍នីមួយៗ ។

(២) ហត្ថលេខីដែលបានតម្កល់លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័តរបស់ខ្លួនមុនកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ នឹងក្លាយជាសមាជិកនៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ ហត្ថលេខីផ្សេងទៀតដែលអនុលោមតាមកថាខណ្ឌ (១) ខាងលើនឹងក្លាយជាសមាជិក AMRO នៅកាលបរិច្ឆេទនៃការតម្កល់លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័តរបស់ខ្លួននៅកន្លែងតម្កល់កិច្ចព្រមព្រៀង ដែលត្រូវជូនដំណឹងដល់សមាជិកដទៃទៀតអំពីការតម្កល់នេះ ។

### មាត្រា ២៦ : ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការតម្កល់លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័តដោយសាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ និងរដ្ឋសមាជិកអាស៊ានយ៉ាងតិចចំនួន ៥ រួមមានសាធារណរដ្ឋសិង្ហបុរីផងដែរ ។

## មាត្រា ២៧ : សមាជិកភាព និងការដកខ្លួនចេញ

(១) សមាជិកភាពនៃ AMRO ត្រូវបើកចំហដល់បណ្តារដ្ឋាភិបាលដែលមានអាជ្ញាធរពាក់ព័ន្ធជាភាគីនៅក្នុងយន្តការហិរញ្ញវត្ថុតំបន់ក្នុងលក្ខខណ្ឌដែលរដ្ឋាភិបាលទាំងនោះ ព្រមទទួលយកកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ហើយអាច និងមានឆន្ទៈអនុវត្តកាតព្វកិច្ចទាំងនោះ ។

(២) បន្ទាប់ពីបានអនុម័តដោយគណៈកម្មាធិការប្រតិបត្តិ ប្រទេសស្នើសុំនឹងក្លាយជាសមាជិកនៅពេលដែលឧបករណ៍នៃការផ្តល់សច្ចាប័ន ការឯកភាព ឬការអនុម័តត្រូវបានតម្កល់នៅកន្លែងតម្កល់កិច្ចព្រមព្រៀង ដែលត្រូវជូនដំណឹងដល់សមាជិកដទៃទៀតអំពីការតម្កល់នេះ ។

(៣) សមាជិកណាមួយដែលអាជ្ញាធរពាក់ព័ន្ធរបស់ខ្លួនលែងជាភាគីក្នុងយន្តការហិរញ្ញវត្ថុតំបន់អាចដកខ្លួនចេញពីសមាជិកភាពរបស់ AMRO គ្រប់ពេលដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ទីស្នាក់ការកណ្តាលរបស់ AMRO ។ សមាជិកដែលបានដកខ្លួនចេញត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចផ្ទាល់និងជាយថាហេតុចំពោះ AMRO តាមកាលបរិច្ឆេទនៃការបញ្ឈប់សមាជិកភាពរបស់ខ្លួន ។

(៤) ការដកខ្លួនរបស់សមាជិកមួយនឹងមានប្រសិទ្ធភាព ហើយសមាជិកភាពនឹងត្រូវបានបញ្ឈប់នៅកាលបរិច្ឆេទដូចមានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង ប៉ុន្តែមិនឱ្យលើសពី ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងនេះត្រូវបានទទួលដោយស្នាក់ការកណ្តាលរបស់ AMRO ។

## មាត្រា ២៨ : កិច្ចរៀបចំនិងសម្របសម្រួលអន្តរកាល

គណៈកម្មាធិការប្រតិបត្តិនឹងត្រួតពិនិត្យលើកិច្ចរៀបចំ និងសម្របសម្រួលអន្តរកាលរវាងក្រុមហ៊ុន AMRO Ltd និង AMRO ។

ជាសក្ខីភាព ហត្ថលេខាខាងក្រោម ដោយមានសិទ្ធិប្រទានផ្តល់ដោយរដ្ឋាភិបាលនៃរដ្ឋសមាជិករៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើនៅ វ៉ាស៊ីនតោន ក្លូឌ្បៀឌីសទ្រីក សហរដ្ឋអាមេរិក នៅ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៤ មួយច្បាប់ដើម ជាភាសាអង់គ្លេស ដែលនឹងត្រូវតម្កល់ទុកនៅអគ្គលេខាធិការនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ អនុលោមតាមមាត្រា ២៤ ។

**ជំនួសមុខឱ្យរាជរដ្ឋាភិបាលប្រ៊ុយណេដារូសាឡាម**

ជិនូ្នសមុខឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋសឹង្ហបុរី

ជិនូ្នសមុខឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

ជិនូ្នសមុខឱ្យរាជរដ្ឋាភិបាលនៃប្រទេសជប៉ុន

ជិនូ្នសមុខឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

ជិនូ្នសមុខឱ្យរដ្ឋាភិបាលហុងកុង ប្រទេសចិន

## តារាង

## ភាគទាន និងការបែងចែកអំណាចក្នុងការបោះឆ្នោត

| | | ភាគទានហិរញ្ញវត្ថុ | | សន្លឹកឆ្នោតមូលដ្ឋាន | បោះឆ្នោតផ្អែកលើ វិភាគទាន | អំណាចបោះឆ្នោតសរុប | |
|---|---|---|---|---|---|---|---|
| | | % | | (ចំនួនសន្លឹកឆ្នោត) | (ចំនួនសន្លឹកឆ្នោត) | ចំនួនសន្លឹក ឆ្នោត | % |
| ចិន | ចិន (មិនរាប់បញ្ចូលហុងកុង) | ៣២,០ | ២៨,៥០ | ៣,២០ | ៦៨,៤០ | ៧១,៦០ | ២៥,៤៣ |
| | ហុងកុង ប្រទេសចិន | | ៣,៥០ | ០,០០ | ៨,៤០ | ៨,៤០ | ២,៩៨ |
| ជប៉ុន | | | ៣២,០០ | ៣,២០ | ៧៦,៨០ | ៨០,០០ | ២៨,៤១ |
| កូរ៉េ | | | ១៦,០០ | ៣,២០ | ៣៨,៤០ | ៤១,៦០ | ១៤,៧៧ |
| **បូក ៣** | | | **៨០,០០** | **៩,៦០** | **១៩២,០០** | **២០១,៦០** | **៧១,៥៩** |
| ឥណ្ឌូនេស៊ី | | | ៣,៧៩៣ | ៣,២០ | ៩,១០៤ | ១២,៣០៤ | ៤,៣៦៩ |
| ថៃ | | | ៣,៧៩៣ | ៣,២០ | ៩,១០៤ | ១២,៣០៤ | ៤,៣៦៩ |
| ម៉ាឡេស៊ី | | | ៣,៧៩៣ | ៣,២០ | ៩,១០៤ | ១២,៣០៤ | ៤,៣៦៩ |
| សឹង្ហបុរី | | | ៣,៧៩៣ | ៣,២០ | ៩,១០៤ | ១២,៣០៤ | ៤,៣៦៩ |
| ហ្វីលីពីន | | | ៣,៧៩៣ | ៣,២០ | ៩,១០៤ | ១២,៣០៤ | ៤,៣៦៩ |
| វៀតណាម | | | ០,៨៣៣ | ៣,២០ | ២,០០ | ៥,២០ | ១,៨៤៧ |
| កម្ពុជា | | | ០,១០០ | ៣,២០ | ០,២៤ | ៣,៤៤ | ១,២២២ |
| មីយ៉ាម៉ា | | | ០,០៥០ | ៣,២០ | ០,១២ | ៣,៣២ | ១,១៧៩ |
| ប្រ៊ុយណេ | | | ០,០២៥ | ៣,២០ | ០,០៦ | ៣,២៦ | ១,១៥៨ |
| ឡាវ | | | ០,០២៥ | ៣,២០ | ០,០៦ | ៣,២៦ | ១,១៥៨ |
| **អាស៊ាន** | | | **២០,០០** | **៣២,០០** | **៤៨,០០០** | **៨០,០០** | **២៨,៤១** |
| **សរុប** | | | **១០០,០០** | **៤១,៦០** | **២៤០,០០** | **២៨១,៦០** | **១០០,០០** |

**Agreement Establishing ASEAN+3 Macroeconomic Research Office ("AMRO")**

THE CONTRACTING PARTIES,

**Recalling** the Chiang Mai Initiative Multilateralisation (hereinafter referred to as "CMIM") to establish a multilateral liquidity support arrangement under the ASEAN+3 framework to address balance-of-payments and short-term liquidity difficulties in the region;

**Whereas** the parties to the CMIM agreed under the CMIM to establish a surveillance unit;

**Recognising** that ASEAN+3 Macroeconomic Research Office Limited (hereinafter referred to as "AMRO Ltd") was established in 2011 on the initiative of the ASEAN+3 Finance Ministers' Meeting;

**Desiring** to constitute AMRO as an international organisation with full legal personality to take over the role of AMRO Ltd so that it can function effectively as an independent surveillance unit in the region; and

**Convinced** that the establishment of AMRO will serve as an important step forward to promote regional financial cooperation through a permanent institution which will underpin regional financial stability together with a strengthened CMIM;

HAVE AGREED AS FOLLOWS:

## CHAPTER 1
## ESTABLISHMENT, PURPOSE AND FUNCTIONS

### Article 1
### Establishment and Members

(1) By this Agreement, the Contracting Parties establish ASEAN+3 Macroeconomic Research Office (hereinafter referred to as "AMRO") as an international organisation which shall have full legal personality and the legal capacity for carrying out its purpose and functions.

(2) The Contracting Parties that have ratified, accepted or approved this Agreement shall be members of AMRO in accordance with Articles 25 and 26.

### Article 2
### Purpose

The purpose of AMRO is to contribute to securing the economic and financial stability of the region through conducting regional economic surveillance and supporting the implementation of the regional financial arrangement. The term "regional financial arrangement" means the multilateral liquidity support arrangement under the ASEAN +3 framework to address potential and actual balance-of-payments and short-term liquidity difficulties in the region.

### Article 3
### Functions

To fulfil its purpose, AMRO shall have the following functions:

(a) to monitor, assess and report to members on their macroeconomic status and financial soundness;

(b) to identify for members macroeconomic and financial risks and vulnerabilities in the region and assist them, if requested, in the timely formulation of policy recommendations to mitigate such risks;

(c) to support members in the implementation of the regional financial arrangement; and

(d) to conduct such other activities necessary for achieving the purpose of AMRO as may be determined by the Executive Committee.

## CHAPTER 2
## OPERATIONS

### Article 4
### Cooperation of Members

(1) Each member shall provide AMRO with relevant information and assistance as may reasonably be required for its surveillance and other activities provided for under Article 3 to the extent permissible under its applicable laws and regulations. Members shall be under no obligation to provide information in such detail that the affairs of individuals or corporations are disclosed.

(2) Each member shall cooperate with AMRO in good faith in AMRO's surveillance and other activities provided for under Article 3.

### Article 5
### Operations

In order to fulfil its purpose and functions under Article 2 and Article 3:

(a) AMRO shall use the information provided by members under Article 4 appropriately;

(b) AMRO may conduct consultations with each member on an annual basis ("Annual Consultation Visits") on such issues as may be relevant to the purpose and functions of AMRO under this Agreement;

(c) AMRO, independently and without undue influence of any member, shall prepare such reports as it deems desirable in carrying out its purpose and functions, and communicate its views informally and confidentially to any member on any matters arising under this Agreement that may affect such member;

(d) AMRO shall publish such reports as it deems desirable for carrying out its purpose and functions in accordance with subparagraph (2) (f) of Article 8; and

(e) AMRO may cooperate with members, international organisations or institutions in related fields within the terms of this Agreement, and enter into agreements with them. No member shall be liable, by reason of its status or participation in AMRO, for acts, omissions or obligations of AMRO arising out of such agreements.

## CHAPTER 3
## GOVERNANCE

### Article 6
### Structure

AMRO shall have an Executive Committee, an Advisory Panel, a Director and staff.

### Article 7
### Executive Committee: Composition

(1) Each member shall be represented on the Executive Committee and for this purpose may appoint up to two

Deputies: one finance deputy from its government with responsibility for finance and one central bank deputy from its central bank or its equivalent. Any such appointment may be revoked at any time by the member that made the appointment.

(2) Each Deputy shall appoint an alternate who shall have full power to act on his or her behalf when the former is not present.

(3) Notwithstanding paragraphs (1) and (2) above, Hong Kong Special Administrative Region of the People's Republic of China (hereinafter referred to as "Hong Kong, China") may appoint one Deputy only.

## Article 8
## Executive Committee: Powers and Procedures

(1) All powers of AMRO under this Agreement that are not otherwise conferred on the Advisory Panel or the Director shall be vested in the Executive Committee.

(2) The Executive Committee shall maintain strategic oversight of and set policy directions for AMRO and, in particular:

(a) review the reports prepared under Article 3 and Article 5 and such other reports and assessments as may be prepared by the Director, including any input provided by the Advisory Panel;

(b) review and approve its annual reports which set out the performance of the functions and duties of AMRO containing an audited statement of AMRO's financial accounts and staffing levels;

(c) review and approve the staffing levels, annual budget, and work programme of AMRO;

(d) oversee the appointment process for, appoint, suspend or terminate the employment of the Director in accordance with Article 11 where necessary, and review the performance of the Director;

(e) appoint the Advisory Panel members, and suspend or terminate any such appointments; and

(f) set the publication policy of AMRO.

(3) The Executive Committee may promulgate such rules, regulations, policies and procedures as may be necessary or appropriate to conduct the business of AMRO.

(4) The Executive Committee may establish such committees as are necessary and appropriate to facilitate the general operations of AMRO.

(5) The Executive Committee shall meet at such frequency and at such place as it may determine and shall be jointly chaired by a Deputy from each of the coordinating countries, which consist of two members, one from among the ASEAN Member States and the other from among the People's Republic of China, Japan and the Republic of Korea.

**Article 9**
**Voting**

(1) A quorum for any meeting of the Executive Committee shall be a majority of the Deputies who, in aggregate, exercise not less than two-thirds of the total voting power as set out in the Schedule to this Agreement.

(2) The decisions of the Executive Committee shall be taken by consensus. If consensus cannot be reached, such decisions of the Executive Committee shall be effective if

approved by no less than two-thirds of the total voting power as set out in the Schedule to this Agreement.

(3) When two Deputies represent one member, they shall cast their votes as a unit. For the avoidance of doubt, the votes of the People's Republic of China and Hong Kong, China shall be cast separately.

## Article 10
## Advisory Panel

(1) The Advisory Panel shall provide timely strategic, technical and professional input to AMRO's macroeconomic assessments and recommendations to the Director.

(2) The Advisory Panel shall be independent from the Director and the staff of AMRO, and shall be accountable to the Executive Committee.

(3) The Advisory Panel shall consist of not more than six members who are distinguished and respected economists under such terms and conditions as the Executive Committee may determine. The Advisory Panel members shall be appointed by the Executive Committee.

## Article 11
## Director and Staff

(1) The Executive Committee shall appoint a Director. The Director shall hold office on such terms as determined by the Executive Committee.

(2) The appointment of the Director shall be guided by the principles of meritocracy, transparency and openness.

(3) The Director shall, unless directed otherwise by the Executive Committee, participate in the meetings of the Executive Committee.

(4) The Director shall:

(a) provide the Executive Committee with periodic assessments of macroeconomic and financial conditions and policies in the region;

(b) be accountable to the Executive Committee and subject to its general control;

(c) be chief of the staff of AMRO and, unless the Executive Committee decides otherwise, be responsible for the organisation, appointment and dismissal of staff and overall performance of AMRO;

(d) represent AMRO and conduct the current business of AMRO;

(e) submit to the Executive Committee an annual report; and

(f) submit to the Executive Committee a plan of the staffing levels, annual budget, and annual work programme of AMRO for review and approval.

(5) The Director and the staff shall, in the discharge of their functions, owe their duty entirely to AMRO and to no other authority. Members shall respect the international character of this duty and shall refrain from all attempts to influence any of the staff in the discharge of these functions.

(6) In appointing the staff, the Director shall, subject to the paramount importance of securing the highest standards of efficiency and of technical competence, pay due regard to the importance of recruiting staff on as wide a regional geographical basis as possible.

## Article 12
## Confidentiality

Deputies and their alternates, members of the Advisory Panel, the Director and staff, experts performing missions for AMRO and any other persons who work or have worked for or in connection with AMRO shall not disclose information that they receive while discharging or purporting to discharge their duties unless approved by the Executive Committee. Their obligation to maintain the confidentiality of such information shall continue after their duties to AMRO have ceased. Throughout this Agreement, the term "experts performing missions for AMRO" refers to professionals carrying out AMRO's purpose and functions under contract with AMRO.

## Article 13
## Budget and Finance

(1) AMRO shall be provided with the necessary financial resources to perform its functions effectively.

(2) AMRO shall establish financial rules and procedures in accordance with international standards. AMRO shall observe sound and prudent financial management policies and practices and budgetary discipline consistent with international best practices.

(3) Office-related expenses shall, on a reasonable basis, be borne by the Republic of Singapore as host country, and shall be remitted in a timely manner.

(4) All remaining expenses (including, but not limited to, human resources-related expenses) shall be borne by members in accordance with their contribution in the proportions set out in the Schedule to this Agreement. The members shall remit their contribution in a timely manner upon approval of their respective annual budgetary appropriations.

(5) AMRO may not borrow funds unless otherwise approved by the Executive Committee.

### Article 14
### Communication

(1) Each member may designate up to two appropriate official entities with which AMRO may communicate in connection with any matter arising under this Agreement. AMRO shall address all such communications to such designated official entities.

(2) Whenever the approval of any member is required under this Agreement before any act may be done by AMRO, approval shall be deemed to have been given unless the member presents a written objection within such reasonable period as the Executive Committee may determine when it notifies the member of the proposed act.

(3) The official language of AMRO shall be English.

### Article 15
### Location

The Headquarters of AMRO shall be located in the Republic of Singapore.

## CHAPTER 4
## STATUS, PRIVILEGES AND IMMUNITIES

### Article 16
### Purposes of Status, Privileges and Immunities

The legal status, privileges, immunities, and exemptions set out in this Agreement shall be accorded to AMRO in the

territory of each member to enable AMRO to effectively exercise its purpose and functions.

### Article 17
### Legal Status of AMRO

AMRO shall have full legal personality and, in particular, full legal capacity to:

(a) enter into contracts;

(b) acquire and dispose of immovable and movable property; and

(c) institute legal proceedings.

### Article 18
### Privileges and Immunities of AMRO

(1) AMRO shall enjoy immunity from every form of legal process except to the extent that it expressly waives its immunity for the purpose of any proceedings or under the terms of any contract.

(2) The property and assets of AMRO shall, wherever located and by whomsoever held, be immune from search, requisition, confiscation, expropriation or any other form of seizure, taking or foreclosure by executive or legislative action.

(3) The archives of AMRO, and all documents belonging to it, or held by it, shall be inviolable.

(4) To the extent necessary to carry out its functions, all property and assets of AMRO shall be free from restrictions, regulations, controls and moratoria of any nature.

(5) Official communications of AMRO shall be accorded by

each member treatment not less favourable than that it accords to the official communications of any other member.

(6) No censorship shall be applied to the official correspondence and other official communications of AMRO. Nothing in this Article shall be construed to preclude the adoption of appropriate security precautions to be determined by agreement between a member and AMRO.

(7) AMRO, its assets, property, income, and its operations and transactions shall be exempt from all taxation and from all customs duties. AMRO shall also be exempt from any obligation for the payment, withholding or collection of any tax or duty. Notwithstanding this, it is understood, however, that AMRO shall not claim exemption from taxes which are, in fact, no more than charges for public utility services.

## Article 19
## Privileges and Immunities of AMRO Personnel

Deputies and their alternates, members of the Advisory Panel, the Director and staff of AMRO, and experts performing missions for AMRO (hereinafter referred to as "AMRO Personnel"):

(a) shall be immune from legal process with respect to words spoken and written and acts performed by them in their official capacity and shall enjoy inviolability in respect of their official papers and documents except when AMRO waives this immunity;

(b) where they are not local citizens or nationals, shall be granted the same immunities from immigration restrictions, alien registration requirements and national service obligations and the same facilities as regards exchange restrictions as are accorded by each member to the representatives and staff of comparable rank of any other member;

